ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ

លេខ: ៥០៦៧ ប្រក

# ប្រកាស
## ស្តីពី
## ការកែសម្រួលប្រការ១ នៃប្រកាសលេខ១៤៦១ ប្រក ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៤ ស្តីពីបែបបទនៃការផ្តល់លិខិតឆ្លងដែនធម្មតា

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ៦៨ អនក្រ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីលិខិតឆ្លងដែន នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ២០២ អនក្រ.បក ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការផ្តល់ និងការប្រើប្រាស់លិខិតឆ្លងដែនការទូត និងផ្លូវការ
- បានឃើញអនុក្រឹត្យលេខ៥៦៩ អនក្រ.បក ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលមាត្រា៨ និងមាត្រា១០ នៃអនុក្រឹត្យលេខ៦៨ អនក្រ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីលិខិតឆ្លងដែន នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ២០៥ អនក្រ.បក ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៤ ស្តីពីការផ្តល់លិខិតឆ្លងដែនធម្មតាជូនពលករ ពលការិនី និងសិស្ស និស្សិតខ្មែរ
- បានឃើញអនុក្រឹត្យលេខ៣០៦ អនក្រ.បក ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការកែសម្រួលមាត្រា១ និងមាត្រា២ នៃអនុក្រឹត្យលេខ២០៥ អនក្រ.បក ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៤ ស្តីពីការផ្តល់លិខិតឆ្លងដែនធម្មតាជូនពលករ ពលការិនី និងសិស្ស និស្សិតខ្មែរ
- បានឃើញប្រកាសលេខ១៤៦១ ប្រក ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៤ ស្តីពីបែបបទ នៃការផ្តល់លិខិតឆ្លងដែនធម្មតា

- យោងតាមសំណូមពរចាំបាច់នៃការងារ

## សម្រេច

**ប្រការមួយ.-**

ប្រការ១ នៃប្រកាសលេខ១៤៦១ ប្រក ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៤ ស្ដីពីបែបបទ នៃការផ្ដល់លិខិតឆ្លងដែនធម្មតា ត្រូវបានកែសម្រួលដូចតទៅៈ

**ប្រការ១.- ថ្មី**

ប្រជាពលរដ្ឋដែលស្នើសុំផ្ដល់លិខិតឆ្លងដែនធម្មតា ត្រូវមានឯកសារច្បាប់ដើមដូចខាងក្រោមៈ

ក.ពលរដ្ឋខ្មែរដែលមានអាយុ១៥ឆ្នាំឡើងត្រូវមាន ៖

- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬ
- សេចក្ដីចម្លងសំបុត្រកំណើត ឬសេចក្ដីចម្លងសំបុត្របញ្ជាក់កំណើត ឬឯកសារផ្សេងទៀតដែលបញ្ជាក់អំពីសញ្ជាតិខ្មែរ។

ខ.កុមារមានអាយុក្រោម១៥ឆ្នាំ ៖

ត្រូវមានសំណើសុំ ឬការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីឪពុក ម្ដាយ ឬអាណាព្យាបាល និងត្រូវភ្ជាប់មកជាមួយនូវសេចក្ដីចម្លងសំបុត្រកំណើត ឬសេចក្ដីចម្លងសំបុត្របញ្ជាក់កំណើត ឬឯកសារផ្សេងទៀតដែលបញ្ជាក់អំពីសញ្ជាតិខ្មែរ។

ករណីដែលប្រជាពលរដ្ឋប្រើប្រាស់សេចក្ដីចម្លងសំបុត្រកំណើត ឬសេចក្ដីចម្លងសំបុត្របញ្ជាក់កំណើត ឬឯកសារផ្សេងទៀតដែលបញ្ជាក់អំពីសញ្ជាតិខ្មែរ ត្រូវភ្ជាប់ជាមួយនូវសៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ ឬលិខិតបញ្ជាក់ទីលំនៅដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ច។

**ប្រការពីរ.-**

បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយពីប្រកាសនេះត្រូវទុកជានិរាករណ៍។

**ប្រការបី.-**

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម អគ្គស្នងការនៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ អគ្គនាយកនៃអគ្គនាយកដ្ឋានភស្តុភារនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល អគ្គនាយកនៃអគ្គនាយកដ្ឋាននានាចំណុះក្រសួងមហាផ្ទៃ អភិបាលរាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែ[illegible] ឆ្នាំ២០១៧

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្ដេចក្រឡាហោម ស ខេង**

**កន្លែងទទួល**

- *ទីស្ដីការគណៈរដ្ឋមន្ត្រី*
- *ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ*
- *ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យសម្ដេច ឯកឧត្ដម លោកជំទាវឧបនាយករដ្ឋមន្ត្រី*
- *ដូចប្រការបី*
- *រាជកិច្ច*
- *ឯកសារ កាលប្បវត្តិ*